# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ: ១៧៥/ន.៧/២០១៥

## សេចក្តីប្រកាសជូនដំណឹង

ដោយបានការឯកភាពជាគោលការណ៍រាជរដ្ឋាភិបាលចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកឧត្តម នាយឧត្តមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់កងយោធពលខេមរភូមិន្ទអញ្ជើញទៅចូលរួមប្រារព្ធពិធីតាមការអញ្ជើញរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនិងកងទ័ពប្រជាជនវៀតណាមតាមកម្មវិធីដូចតទៅៈ

ចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៥ អញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីមហាមិទ្ទិញធ្វើព្យុហយាត្រាដើម្បីអបអរសាទរខួបលើកទី៤០ នៃទិវាបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ( ២ ធ្នូ ១៩៧៥ - ២ ធ្នូ ២០១៥ ) ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០១៥ នៃរដ្ឋធានីវៀងច័ន្ទ ប្រទេសឡាវ ។

ក្នុងអំឡុងពេលចូលរួមប្រារព្ធពិធីខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** នឹងចូលជួបសម្តែងការគួរសមជាមួយ ឯកឧត្តម **Thongsing THAMMAVONG** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ផងដែរ ។

សមាជិក គណៈប្រតិភូ អមដំណើរ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** អញ្ជើញចូលរួមពិធី ខាងលើរួមមាន ឯកឧត្តម នាយឧត្តមសេនីយ៍ **ណឹម សុវត្ថិ** អគ្គនាយកនយោបាយ និងកិច្ចការបរទេស ឯកឧត្តម នាយឧត្តមសេនីយ៍ **ទៀ វិញ** មេបញ្ជាការកងទ័ពជើងទឹក ព្រមទាំងឯកឧត្តម អស់លោកជានាយទាហានមួយចំនួនទៀត ។

ចាប់ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៥ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** នឹងដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមក្នុងពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៧០ (១០ ធ្នូ ១៩៤៥-១០ ធ្នូ ២០១៥) ថ្ងៃប្រពៃណីបង្កើតកងប្រដាប់អាវុធភូមិភាគ៧ កលទ័ពប្រជាជនវៀតណាម ដែលនឹងប្រព្រឹត្ត ទៅនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៥ នៅទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម ។

ក្នុងពិធីនេះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** នឹងបំពាក់គ្រឿងឥស្សរយសជូនដល់ស្ថា ប័ន អង្គភាព និងនាយទាហានមួយចំនួននៃកងឯកភាពភូមិភាគ៧ កងទ័ពប្រជាជនវៀតណាម ដែលមានស្នាដៃឆ្នើមលើវិស័យកិច្ចសហប្រតិបត្តិការយោធា តាមរយៈការជួយគាំទ្រឧបត្ថម្ភទាំងស្មារតី និង សម្ភារៈ ព្រមទាំងពង្រឹង-ពង្រីកចំណងសាមគ្គីភាព មិត្តភាពដ៏ល្អប្រសើររវាងកងទ័ពនៃប្រទេសទាំងពីរ កម្ពុជា-វៀតណាម នាពេលកន្លងមក។

សមាជិកគណៈប្រតិភូអមដំណើរ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** អញ្ជើញចូលរួមពិធីខាងលើរួមមាន ថ្នាក់ដឹកនាំក្រសួងការពារជាតិ អគ្គបញ្ជាការ និងប្រធានស្ថាប័នចំណុះ ព្រមទាំងមេបញ្ជាការគ្រប់យោធភូមិភាគក៏អញ្ជើញចូលរួមផងដែរ ៕

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០១៥